# ការសំភាសន៍របស់អ្នកមីង ចាន់ សុខឃីម

កៈ អ្នកធ្វើការសំភាសន៍ ស៊ុន ភីនិច ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ ចាន់ មិថុនា(ចៅ)

គៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ ចាន់ សុខឃីម

កៈ អញ្ចឹងខ្ញុំអរគុណអ៊ុំសំរាប់ពេលវេលាថ្ងៃនេះដែលបានផ្តល់ឱកាសដើម្បីខ្ញុំអាចសំភាសន៍ជាមួយនិងអ៊ុំអញ្ចឹងណឹស។ខ្ញុំដឹងថាការសំភាសន៍មួយនេះគឺជាការបង្កើតឡើងដោយសកលវិទ្យាល័យមួយនៅក្នុងសហរដ្ឋអាមេរិកដែលគេហៅកាត់ថាប៊ីវ៉ាយយូអញ្ចឹងគេបង្កើតឡើងដើម្បីជួបដល់អ៊ុំអាចរក្សាប្រវត្តិទុកឲ្យកូនចៅអ៊ុំជំនាន់ក្រោយឲ្យគាត់យល់។

គៈ គេសំភាសន៍ម្តេចទៅ? សំភាសន៍ដែលពាក់ព័ន្ធជាមួយនិងក្រុមគ្រួសារនិងអី។

កៈ ហើយវាជាឱកាសមួយសំរាប់ឲ្យពួកគាត់រៀនសូត្រពីអ៊ុំដែរ។ ថ្ងៃនេះគឺ ការសំភាសន៍ធ្វើឡើងនៅ ថ្ងៃទី០៣ ខែ០៥ ឆ្នាំ២០១៧ ហើយសំភាសន៍ដោយខ្ញុំផ្ទាល់ដោយស៊ុន ភីនិច និងចូលរួមចៅរបស់អ៊ុំដែរ! អូនប្រាប់អ្នកគ្រូតិចមើលឈ្មោះអីគេកូន?

ខៈ ឈ្មោះ ចាន់ មិថុនា។

កៈ ស្អីគេ ចាន់ មិថុនា។ អាយុប៉ុន្មានហើយ?

ខៈ អាយុ ៣ឆ្នាំជាង។

កៈ ៣ឆ្នាំជាង! ហើយអ៊ុំអាចប្រាប់ឈ្មោះពេញរបស់អ៊ុំដល់ខ្ញុំបានទេ?

គៈ បើដាក់នៅក្នុងអត្តសញ្ញាណប័ត្រវាឈ្មោះ ចាន់សុខឃីមនិងឯងតែខ្ញុំអត់ពេញចិត្តទេឈ្មោះនិងនោះបើឈ្មោះខ្ញុំពីដើមគេតែងហៅថា អាធី,អាធី អញ្ចឹងណឹសជំនាន់ប៉ែតជាងនិងគឺវៀតណាមដាក់ឈ្មោះឲ្យអញ្ចឹងណឹសអញ្ចឹងឈ្មោះអាធីហើយក្រោយមកម្តាយខ្ញុំក៏ហៅខ្ញុំថាអានាង,អានាងអញ្ចឹងទៅក៏ខ្ញុំមានបងខ្ញុំម្នាក់ពេញចិត្តឈ្មោះអានាងអានាងហើយគាត់ស្រលាញ់ក៏ហៅឈ្មោះនិងទៅនិងអញ្ចឹងឈ្មោះខ្ញុំវាចូល៣ឈ្មោះហើយ។អញ្ចឹងឈ្មោះអាធីទី១ឆ្នាំប៉ែតគត់មកគេហៅខ្ញុំអាធី,អាធីខេត្តសៀមរាបនិងណឹសអញ្ចឹងខ្ញុំមានការទំនាក់ទំនងច្រើនជាមួយនិងគាត់ហើយអ្នកគេស្រលាញ់និងក៏គេចូលចិត្តហៅឈ្មោះនិងដែរហៅតាមឈ្មោះនិងវៀតណាមគេដាក់ឲ្យនិងអាធីអាធីនិ

ងដល់ក្រោយមកទៀតម្ដាយខ្ញុំហៅខ្ញុំនាងនាងនិងអញ្ជឹងទៅណ៎!បងធម៌នៅកាលណាជានិងគាត់ហៅខ្ញុំអានាងអានាង,សុខនាងអញ្ជឹងទៅ។មួយហៅអាធីមួយហៅអានាងដល់ក្នុងអត្តសញ្ញាណប័ត្រហៅថាសុខឃីមហើយគេស្គាល់ថាសុខឃីម,សុខឃីមអញ្ជឹងទៅហើយបើឈ្មោះក្នុងសាសនាចក្រនេះ ទៀត កន្លែងព្រះនេះទៀតក៏គេស្គាល់ថា ឃីម, ឃីម ឬសុខឃីម, សុខឃីម អញ្ជឹងទៅណឹស។

ក៖ អញ្ជឹងសំរាប់អ៊ុំពេញចិត្តឈ្មោះមួយណាជាងគេឈ្មោះចំនួនបីនិង?

គ៖ និយាយទៅខ្ញុំស្ដាយណាស់អ្នកដែលស្គាល់ខ្ញុំពីដើមមកគាត់មិនឲ្យខ្ញុំដូរឈ្មោះនិងភ្លេចណឹសបាត់ការចង់ចាំខ្ញុំក៏មិនបានប្រាប់ម្ដាយខ្ញុំព្រោះកាលដែលគេហៅអញ្ជឹងអត់ព្រាងទុកនិយាយទៅពេលអ្នកដែលស្គាល់មួយចំនួននិងដល់ពេលគេហៅអញ្ជឹងដូចថាគេហៅមួយចំនួនស្គាល់តែឈ្មោះនិងដល់ពេលគេចង់រកយើងរកម្ដេចឃើញគេប្រាប់យើងដែរគេថាហាមកុំឲ្យដូរឈ្មោះឈ្មោះអីឈ្មោះនិងទៅ។ស្រលាញ់ឈ្មោះនិងតែដល់ខ្ញុំអញ្ជឹងខ្ញុំពិបាកពិបាកក្នុងការអញ្ជឹងខ្ញុំមិនចង់ដូរទេប៉ុន្តែមិនដឹងជាយ៉ាងម្ដេចម្ដាយខ្ញុំពេលគាត់ចុះអត្តសញ្ញាណប័ត្រគាត់គាត់ទៅចុះខ្លួនគាត់គាត់ដាក់ខ្លួនគាត់អញ្ជឹងណឹស គាត់ឲ្យខ្ញុំដាក់ឈ្មោះនិងទៅខ្ញុំក៏ភ្លេចគិតអ្នកដែលប្រាប់ពីមុនមកភ្លេចគិតអាកន្លែងនិងហាមកុំឲ្យដូរឈ្មោះអញ្ជឹង ណឹស ស្រណុកគេចង់រកយើងគេរកម្ដេចឃើញ។

ក៖ ឧទាហរណ៍អ៊ុំ នៅលើអត្តសញ្ញាណប័ត្រស្រីនាង គេមករកឈ្មោះធីគិតម្ដេចទៅ?

គ៖ អញ្ជឹងបានថាខ្ញុំពិបាកអញ្ជឹងខ្ញុំកំពុងស្រាវជ្រាវមួយរក បងខ្ញុំនិងឯងបងទី១គាត់ហៅខ្ញុំអាធីអាធីហើយបងទី២គាត់ហៅខ្ញុំ អានាង អានាង។ ឥឡូវយើងដឹងអាធី ឬអានាងឬសុខនាងអញ្ជឹងទៅ។

ក៖ ឬមួយក៏ដាក់ថាសុធីស្រីនាងអញ្ជឹងទៅទាំងពីរនិងចូលគ្នាទៅ។ហើយអ៊ុំអាយុប៉ុន្មានហើយឆ្នាំនិង?

គ៖ ក្នុងអត្តសញ្ញាណប័ត្រម្ដាយខ្ញុំពិតប្រាកដការពិតគាត់អត់ចង់ប្រាប់អាយុខ្ញុំ ឆ្នាំខ្ញុំម្ដាយខ្ញុំទេរបៀបដូចថាគាត់ចាស់បុរាណគាត់កាន់អាររបៀបដូចថាបុរាណពីដើមណឹសគាត់មិនងាយប្រាប់ឆ្នាំកូនឲ្យដឹងច្បាស់ទេហើយខ្ញុំសើបសួរគាត់ទៅគាត់និយាយដូចស្រពិចស្រពឹលអញ្ជឹងណឹសប៉ុន្តែដល់អត្តសញ្ញាណប័ត្រគាត់ដាក់នៅក្នុងនិងអាយុគាត់គាត់ដាក់និងគាត់៥០ជាងនិងគាត់ដាក់ក្នុងនិងខ្លួនគាត់ណឹសគាត់និយាយខ្លួនគាត់ហើយខ្ញុំសួរគាត់ឆ្នាំគាត់និងគាត់អត់ប្រាប់ច្បាស់ទេសូម្បីតែអាយុគាត់អត់ចង់ប្រាប់កូនដែរគាត់ថាខ្លាចគេធ្វើអំពើអីអញ្ជឹងណឹសអត់ប្រាប់កូនឲ្យច្បាស់ៗទេខែថ្ងៃ

បើថ្ងៃខ្ញុំដឹងច្បាស់ព្រោះគាត់និយាយប្រាប់គ្នាគាត់ណឹសកើតថ្ងៃអីម៉ោងម្មានអីអានិងខ្ញុំដឹងច្បាស់ម៉ង។

កៈ ថ្ងៃទីប៉ុន្មានអ៊ុំ?

គៈ អេ៎!អត់ទេអាថ្ងៃនិងដូចថ្ងៃសៅរ៍ អាទិត្យយើងនិងណឹសអង្គារអីអញ្ចឹងអត់ដឹងទេ ដឹងតា
ថ្ងៃអាទិត្យម៉ោង៥ល្ងាច ពេលនិងកើតខ្ញុំគាត់ថាពិបាកណាស់ឈឺពោះប៉ុន្មានខែណ៎!
បីបួនថ្ងៃប្រាំថ្ងៃណ៎! ចូល៥ថ្ងៃ។

កៈ ចុះឆ្នាំខែអ៊ុំដូចជាជូត ឆ្លៅ ខាលអីអញ្ចឹងណឹស?

គៈ គាត់អត់ប្រាប់ច្បាស់គ្រាន់តែអត្តសញ្ញាណប័ត្រគាត់ធ្វើគាត់ទុកខ្លួនគាត់។គាត់អង្គុយរៀបរាប់ព្រោះខ្ញុំអត់ដឹងនោះគាត់អង្គុយនិងមិនមែនធ្វើតែគាត់ណាធ្វើទាំងខ្ញុំផងអាកូនមានប៉ុន្មានគាត់រៀបរាប់ប្រាប់គេអស់កូនវាច្រើនដល់ពេលអញ្ចឹងគាត់ប្រាប់ឆ្នាំកូនទាំងអស់ឲ្យគេដឹងឲ្យគេអ្នកសរសេរឲ្យណឹស អញ្ចឹ ងខ្ញុំចាំតែយកអត្តសញ្ញាណប័ត្រនិងមកប្រើមកប្រើតាមគាត់ទៅ។

កៈ តែបើអាយុក្នុងអត្តសញ្ញាណប័ត្របាជាងណោះអ៊ុំ?តែវ័យអ៊ុំក៏មិនដល់៥០ដែរមើលទៅប្រហែល៤៨, ៤៩អីនិង។

គៈ  កូនៗនិងកុំរៀនគាត់ចូលបន្ទោសណាស់អារឿងនិងគាត់ថាម្តេចគាត់ចូលចិត្តប្រាប់ឆ្នាំគេត្រង់ៗអញ្ចឹងណ៎!ឆ្ងល់ដល់ហើយប្រាប់ខែនេះឆ្នាំនេះគាត់និយាយណឹសគាត់អត់ឲ្យប្រាប់ត្រង់ទេគាត់យើញច្បាស់និងភ្នែកអាប្រាប់ត្រង់និងអាអ្នកចេះអំពើអាវាចង់ធ្វើអីយើងណឹសធ្វើត្រូវងាយណាស់គាត់និយាយអញ្ចឹងឆ្នាំគាត់ខែគាត់ថ្ងៃគាត់និងខ្ញុំអត់ដឹងទេអត់ដឹងសោះហើយទើបតែដឹងដែរដឹងព្រាវៗណឹសត្បិតថាគាត់ឈឺហើយនេះក៏មិនដឹងឆ្នាំខ្ញុំសួរថាម៉ែម៉ែប្រាប់កូនមកម៉ែឆ្នាំអីទើបតែគាត់បង្ហើបនិង គាត់ចេះនិ យាយណឹស ឆ្នាំរោង អញ្ចឹងណឹស ហើយមិនដឹងរោងមែនមិនមែនបើគាត់និយាយអត់ទេគឺថាដាច់ខាតតែម្តងអារឿងឆ្នាំនេះមួយប្រាប់កូនថាតាប្រាប់វាវាយកទៅប្រាប់គេអស់ហើយគាត់ថាអញ្ចឹងឯង គាត់និ យាយថាអញ្ចឹង។ លាក់ធ្វើអី ប្រយ័ត្នណឹសអារឿងខែថ្ងៃឆ្នាំនេះឯង
ឆ្នាំគេធ្វើត្រូវងាយណាស់កូនឯងក៏ចូ លចិត្តប្រាប់ឆ្នាំគេត្រង់ៗម្លេះគាត់ថាអញ្ចឹង។

កៈ ហើយស្រុកកំណើតអ៊ុំនៅឯណាដែរ?

គៈនិយាយពីស្រុកកំណើតម្តាយខ្ញុំឪពុកម្តាយខ្ញុំនៅខេត្តពោធិ៍សាត់និងឯង។ចាំ!ដល់ពេលកើតខ្ញុំមិនមែនកើតនៅពោធិ៍សាត់ទេគឺគាត់កាលណុងសម័យទាហ៊ានអាដល់អញ្ចឹងគាត់ដើរតាមតាគាត់មាននៅក្នុងខេត្តយើងស្រុកយើងនិងទេណឹសគាត់ដើរទៅខេត្តនេះទៅខេត្តនោះអញ្ចឹងទៅគាត់ទៅតា

មទៅតាមឪពុកគាត់ដល់គាត់ទៅតាមឪពុកគាត់ខ្ញុំទៅចាប់កំណើតនៅស្រុកគេចាំ!គាត់និយាយណឹសមិនមែនទៅចាប់កំណើតនៅខេត្តពោធិ៍សាត់នេះទេគាត់និយាយពីប្រវត្តិដែលថាគាត់ចង់បានកូនឃើញគេទៅសុំកូនបន្ទាប់មកក៏ទៅតាមគេដែរគេបបួលគាត់ទៅសុំអីគេភ្នំលង្វែកគេនោះចង់បានកូនខេត្តលង្វែកគេណឹសគេមានភ្នំមួយនិងហើយរួចហើយគាត់ថាក៏ចូលទៅសុំសុំពូកែណាស់អានិងគាត់និយាយពីសម័យពីដើមខ្ញុំចេះតែស្តាប់ទៅគាត់ចេះតែនិយាយពីកន្លែងនិងមីនិងមីនិងកូនសុំព្រះតើ!និយាយអីមិនបានទេមីនិងគាត់ថាឲ្យខ្ញុំពេលឈ្លោះជាមួយខ្ញុំទេដូចថាគាត់ស្រលាញ់កូនអញ្ចឹងណឹសគាត់ចូលចិត្តកាន់ជើងកូនគាត់ប្តីមុនអញ្ចឹងណឹសដូចថាឪពុកចុងខ្ញុំអញ្ចឹងណឹសដូចថាខ្ញុំនិយាយអីមិនបានទេខ្ញុំទឹកភ្នែកហើយទឹកភ្នែកព្រិចៗអញ្ចឹងណឹស។ដូចប្រកែកជាមួយគាត់អញ្ចឹងណឹសនិយាយអីអត់ស្តាប់ទេពីកូនសុំព្រះនិងណាអញ្ចឹងគាត់យាយដល់ពេលគាត់ជួបគ្នាបានខ្ញុំដឹងថាខ្ញុំអត់បានកើតនៅស្រុកនិងទេខេត្តពោធិ៍សា ត់និងទេ កើតនៅស្អីនោះខាងក្រចេះនោះ
ខ្ញុំកើតនៅស្រុកក្រចេះ និងឯង។

ក៖ ក្រុងឧដ្តុង។

គ៖ គាត់ថាទៅសុំព្រះទៅតាមគេថ្ងៃថ្ងៃប្រហែលជារសៀលម៉ោង៣ម៉ោង២ម៉ោង៣និងឯងទៅដល់វត្ត និងឯងគេថាពូកែណាស់សុំដឹងតែបានហើយថារន្ទះមកអោយក្តាំងៗចូលទៅសុំណឹសសុំអញ្ចឹសសោះហេតុអីបានជារន្ទះមកដល់ពេល!(កំពុងតែថាចង់ឲ្យរៀននិងណឹសឲ្យចេះទៅកុំឲ្យវាល្ងង់ឲ្យវាចេះនិង គេស្គាល់ព្រះស្គាល់អីអញ្ចឹងណឹស បណ្តុសពីតូចអញ្ចឹង យើងវាខ្វះខាតពិបាក)។

ក៖ អ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរ?

គ៖ បងប្អូនឪពុកម្តាយខ្ញុំមានច្រើនដែរមានតែបងប្អូនច្រើនគ្មានបានប្រយោជន៍អី។វាអត់មានន័យណឹសអញ្ចឹងស្រុកគេខេត្តគេនិងចូលខេត្តគេហើយមិនមែនខេត្តយើងទេដូចថាយើងរស់នៅផ្ញើរខ្លួនណឹស ។

ក៖ អ៊ុំជាកូនទីប៉ុន្មានក្នុងគ្រួសារ?

គ៖ កូនទី១។

ក៖ កូនទី១ណឹស។

គ៖ ក្រៅពីនិងសុទ្ធតែជាកូនៗទាំងអស់ នៅស្រុកស្រែហើយគេបានប្តីបានប្រពន្ធ ខ្លះគេទៅនៅថៃទៅគេអត់ខ្វាយខ្វល់ពីយើងគេមានរដូវការបុណ្យទានអីគេគិតគូរតែប្អូនគេនោះគិតគូរតែប្អូនគេ

ផ្ញើរលុយផ្ញើរកាក់តិចច្រើនអីហើយគេផ្ញើរតែបងប្អូនគេនោះទេគេអត់សូវសួររកទេនិងហើយខ្ញុំកាន់ព្រះអង្គហើយខ្ញុំនិយាយពិតអាម៉ាសាណានោះគេឲ្យខ្ញុំម្ដងជួបការកូនប្អូនណឹសប្អូនទីប៉ុន្មានទេទី៥អីទៅការទៅក៏ជួបហើយគេឲ្យប៉ុន្មានមឺនម្ដងបីបួនមឺនម្ដងឲ្យម្ដងនិងឯងជួបបានម្ដងឲ្យពរឲ្យជ័យគេទៅហើយគេទៅបាត់ហើយគេមិនសូវសួររកយើងទេបើគេស្រលាញ់យើងជាបងគេឧស្សាហ៍សួរហើយណឹសអត់អត់ខ្វាយខ្វល់យើងផងសូម្បីតែអាអ្នកនៅបាត់ដំបងរាល់ថ្ងៃគេមិនសូវខ្វាយខ្វល់ផងគេទទួលម៉ាភ្លែតៗអញ្ចឹងណឹសទៅក៏ហើយទៅគេមិនសូវខ្វល់ណឹស។ចង់និយាយថាបងប្អូនខ្លះគេគិតគ្នាណឹសនេះអត់គិតយើងទេបងប្អូនវាមានប្រហែលជាង១០នាក់ដែរតែស្លាប់អស់ប៉ុន្មាននាក់ហើយស្លាប់អស់៣,៤ហើយអញ្ចឹងរស់នៅទាំងអស់និងអាខ្លះគេនៅភ្នំពេញចាំ!ខ្លះគេទៅរកស៊ីនៅថៃខ្លះគេនៅបាត់ដំបងខេត្តបាត់ដំបងហើយគេចេញទៅថៃទៅអីអញ្ចឹងទៅហើយមានកូនបន្តទៀតអញ្ចឹងទៅមានតែទៅរកស៊ីនៅថៃនិងឯងរាល់ថ្ងៃមាននាមតែថាបងប្អូននិងឯងហើយសំរាប់ខ្ញុំទេមានន័យអីទេពេលណាគេនឹកឃើញអញ្ចឹងទៅម្ដងម៉ាយាមអញ្ចឹងទៅណឹសគេមិនសូវគិត។អញ្ចឹងខ្លួនខ្ញុំសព្វថ្ងៃនិងគិតតែ២,៣នាក់កូនហើយចៅនេះខ្ញុំភ័យដែរប្រសិនបើមានការអីឈឺគ្រុនរងាអីឬក៏មានបញ្ហាអីអញ្ចឹងមិនដឹងជាទៅផ្លូវណាទេគិតដែរនិងណាខ្វាយខ្វល់ដែរនិងនៅតែ៣នាក់ម៉ែកូនម្ដាយបើសិនជាមានបញ្ហាអីមិនដឹងជារកនៅណាទេ។ខ្លួនឯងពិបាកមែនទែនមែនម៉ងហើយតាមកូនខ្ញុំវានិយាយអញ្ចឹងដែរថាបើព្រះទុកឲ្យរស់ហើយរស់នៅចេះតែបានសុខទៅៗតាមនិងទៅតែបើសិនជាយើងមានបញ្ហាអីកើតឡើងឈឺស្កាត់យប់ព្រលប់អីទៅតាមដំណើរទៅបើយើងអត់មានអីទីពឹងអត់មានអីសង្ឃឹមទេផ្ទះក៏ជួលគេអូនឯងគិតមើលទៅនៅប៉ុន្មានឆ្នាំហើយនេះជាង១០ឆ្នាំហើយឡើងចង់គេធុញហើយដឹងរាល់ថ្ងៃនេះគេថាយើងមិនចេះទៅណាសោះអាងបានគេវាយទំលុះអញ្ចឹងបានថារស់នៅក៏វាអត់សប្បាយចិត្តដែរនៅផ្ទះជួលហើយមានលុយឲ្យគេដែរក៏យើងអត់សប្បាយចិត្តដែរ។យើងថានៅកន្លែងនេះវាបានសុខបានស្រួលហើយណឹសថាវាជិតកន្លែងជិតផ្សារអីកន្លែងប្រជុំជនហើយវាអត់ស្រួលគេធុញគេអីអញ្ចឹងណឹសទៅកន្លែងផ្សេងវាថ្លៃយើងអត់មានលទ្ធភាពទេព្រួយបារម្ភណឹស។

ក៖ ម្ដាយរបស់អ៊ុំមានឈ្មោះអ្វីដែរ?

គ៖ ឆេង មុតលី។

ក៖ ចុះលោកឪពុកវិញ?

គ៖ លោកឪពុកបង្កើតខ្ញុំវិញ ស៊ុន សួនអីមិនដឹងលីតែគាត់និយាយទេតែខ្ញុំមិនដឹង។ ចាំ! គាត់អ្នកស្រុក កំពុងចាម។

កៈ  កំពុងចាម!

គៈ  ចាំ!ឪពុកបង្កើតខ្ញុំ!មានយាយម្នាក់គាត់ស្គាល់ហើយខ្ញុំបំរុងទៅសួរគាត់នេះគាត់ស្គាល់ស្រុកភូមិខាងឪពុកខ្ញុំណឹស!អើ!មិនចេះតិចឆ្នាំទេជាប់៣,៤,៥ឆ្នាំចង់នាំខ្ញុំឲ្យស្គាល់ណែគាត់ជាពួកម៉ាកម្ដាយខ្ញុំដែលធ្លាប់ដើរជាមួយគ្នាពីដើមណឹសតែម្ដាយខ្ញុំគាត់ស្លាប់មុននៅតែគាត់ហើយចង់នាំខ្ញុំឲ្យស្គាល់អ៊ុំខាងឪពុកនិងដែរតែអ៊ុំស្លាប់បាត់ទៀតទៅអញ្ចឹងទៅអញ្ចឹងគាត់ក៏ខ្ជិលទៅកុំអីគាត់ចង់នាំទៅឲ្យស្គាល់បានយាយបង្ហើបណឹសហើយវាអត់ចេះសួរអ៊ុំនៅណាស្រុកអីអ៊ុំស្គាល់ឪពុកបង្កើតខ្ញុំឈ្មោះអីអត់បានសួរកន្លែងនិងឲ្យខ្ញុំមានលុយមានកាក់តិចទៅខ្ញុំនិងទៅសួរគាត់មិនដឹងជាគាត់នៅរស់ឬក៏អាម្ដេចអាម៉ាទៅហើយទេតែបើបានសួរគាត់ប្រហែលគាត់ដឹងខ្លះៗពីចាស់ដែរណឹសបើបានសួរគាត់ដឹងខ្លះៗខាងឪពុកបង្កើតព្រោះម្ដាយខ្ញុំនិងឪពុកខ្ញុំបង្កើតនិងលែងលះគ្នាតាំងពីរខ្ញុំនៅតូចដែរនិងរហូតមកដល់បានប្ដីក្រោយមកកូនឡើង៤, ៥ទៀត។

កៈ ម្ដាយអ្នកស្រុកពោធិ៍សាត់?

គៈ ចាំ! ម្ដាយខ្ញុំអ្នកខេត្តពោធិ៍សាត់ ដល់គាត់បានគ្រួសារក្រោយ១ទៀតណឹសដល់គ្រួសារមុននោះឪពុកខ្ញុំបង្កើតបែកគ្នាទៅតាំងពីខ្ញុំនៅតូចៗនិងណឹសបែកគ្នាហើយគាត់តាមរកគ្នាដែរនិងតែម្ដេចគាត់មិនជួបគ្នាក្រោយមកគាត់យកប្ដីក្រោយទៅបានកូនបានថៅមកម៉ាកំប្លុសក្រោយមកខ្ញុំបានជួបឪពុកខ្ញុំម្ដងដែរនិងសម័យមុនមុន៣ឆ្នាំមកជួបខ្ញុំខ្ញុំអាយុប្រហែល៩ឆ្នាំ១០ឆ្នាំនិងថា១០ឆ្នាំចុះមកលើកបីខ្ញុំខ្ញុំចាំដែរមករកខ្ញុំជួបឪពុកបានបន្តិចនិងឯងដល់ពេលចូលស្រុកសង្គ្រាម៣ឆ្នាំទៅក៏បាត់គាត់ស្លាប់ទៅណឹស ស្លាប់ បាត់ទៅ។

កៈ ប៉ុន្តែសព្វថ្ងៃអត់ដឹងគាត់រស់ឬ ស្លាប់ទេ?

គៈ គាត់ស្លាប់ហើយ។ ព្រោះអី៣ឆ្នាំម្លេះបើគាត់នៅរស់ក៏មករកដែរ ចាំ! គាត់ជួបខ្ញុំយូរហើយ។ គាត់ស្លាប់អស់ហើយបើគាត់នៅក៏គាត់ចាស់ៗអស់ហើយយើងចំណាស់នេះដែរហើយណោះ។អញ្ចឹងគាត់បែកគ្នាតាំងពីខ្ញុំនៅតូចគាត់ស្វែងរកដែរនិងហើយខ្ញុំនៅជាមួយគេនិង។ចាំ!ពីដើមជីវិតរបស់ខ្ញុំរស់នៅតែជាមួយគេក្រហើយគាត់យកខ្ញុំទៅទុកជាមួយគេទៅឲ្យជួយតែជីវិតគាត់អញ្ចឹងណឹសចាំ!ជួយដោះទាល់នៅក្រុមគ្រួសារគាត់មានអីគាត់យកខ្ញុំទៅទុកជាមួយគេនិងអញ្ចឹងខ្ញុំនៅជាមួយគេតាំងពីអាយុនិយាយទៅតាំងពីតូចចាប់ពីខ្ញុំដឹងក្ដីពេលណាមកខ្ញុំនៅជាមួយគេចាំ!ព្រោះអីគាត់បានដូចថាលុយកាក់អីដោយសារខ្ញុំដែរនិងអត់ទាន់ដឹងក្ដីអីទេអត់បានរៀនសូត្រជ្រៅជ្រះអីទេតិចតាំងពីខ្ញុំចេះតែឈ្លៀតខ្លួនឯងទៅដល់មានកូនហើយខ្ញុំឈ្លៀតតិចៗណឹសជីវិតរបស់ខ្ញុំខ្ញុំអត់ចង់និយាយទេតាខ្ញុំនិយាយខ្ញុំចង់តែកំសត់ខ្ញុំរស់នៅជាមួយគេគេវាយធ្វើបាបមិនដែលបាននៅជាមួយម្ដាយ

ឪពុកខ្ញុំបង្កើតទេគេចេះតែចង់វាយក្បាលហូរឈាមស្រក់តក់ៗម្ដេចក៏ឃើញដែរហើយដល់ពេលហើយគាត់យកខ្ញុំទៅទុកនេះតិចទៅទៅទុកនេះតិចទៅនៅនេះមិនត្រូវគាត់ចេះតែសួរកូនឯងទៅនៅជាមួយអ្នកនោះផ្សេងសាកមើលទៀតអីនៅជាមួយគេសុទ្ធតែអ្នកមានអីអញ្ចឹងណឹសយកខ្ញុំទៅនៅជាមួយអ្នកផ្សេងជាមួយគេរាងដូចមិនស្រួលគាត់ថាកូនឯងឯណោះគេទាញយកកូនស្រីនោះមើលទៅវាដូចជាមាំមួនគេអាចប្រើបានម្នាក់នោះគេឲ្យហៅមកយកមកនៅជាមួយគាត់នេះវិញក៏យកទៅនៅឡើង២,៣កន្លែង។គាត់ដើរយកទៅទុកនេះតិចនេះតិច ស្រួ លជាងនេះណឹសចាក់សោទៅបាត់ទៅឲ្យយើងនៅតែក្រៅផ្ទះខ្ញុំជំរះស្មៅអើ!នៅតូចសោះខ្ញុំនៅចាំអត់ដឹងគាត់យកលុយគេប៉ុន្មានៗទេខ្ញុំអត់ដឹងទេណឹសដើម្បីដោះស្រាយជីវិតខ្លួនគាត់ដែលគាត់មានប្ដីក្រោយកូនអីទៀតអីនោះដូចថាគាត់ដាច់ណឹសគេហៅថាដាច់ម្ដងៗអញ្ចឹងទៅគាត់ពឹងផ្អែកលើខ្ញុំដែរអញ្ចឹងណឹសយកកូនទៅទុកហើយគេឲ្យលុយមកដោះស្រាយទៅ។ហើយគេដាក់កំរិតឲ្យខ្ញុំជំរះស្មៅនៅតូចសោះជំរះស្មៅគេវាស់ដូចជំនាន់អាពតអញ្ចឹងណឹសគេវាស់ម៉ែត្ររួចហើយម៉ាព្រឹកនេះនាងឯងត្រូវធ្វើស្មៅនេះប៉ុន្នេះៗ។ខ្ញុំក្មេងចេះតែធ្វើចេះតែឈូសៗទៅជួនកាលឈូសអត់អស់ទេវានៅខ្លះអញ្ចឹងទៅអញ្ចឹងយើងចង់លេងចង់អីផងវានៅក្មេងនិងណាំវាមិនដូចយើងមនុស្សធំណាគេដាក់កំរិតកុំឲ្យយើងខាតណឹសអញ្ចឹងយើងនៅផ្ទះគេយើងញុំាបាយផ្ទះគេគេមិនឲ្យយើងខាតទេហើយម្ដាយយើងយកលុយគេទៀតអញ្ចឹងគេអត់ឲ្យយើងខាតទេគេប្រើយើងហើយខ្ញុំចាំនៅខេត្តពោធិ៍សាត់ទៅស្រុកទៅលេងកូនចៅគាត់នៅឯណាទេប្រើយើងធ្វើអីក៏បានដែរយកទៅតាមអញ្ចឹងទុកវាមិនកើតផ្ទះគេត្រូវការចាក់សោរចាក់អីអញ្ចឹងណឹសដាំបាយដាំអីខ្លាចឆេះផ្ទះឆេះអីអញ្ចឹងដល់ពេលទៅណាអញ្ចឹងគាត់យកយើងទៅដែរ។ជួនណាគាត់ទៅលេងកូនគាត់អញ្ចឹងណឹសដល់ពេលមកវិញគាត់យកយើងមកវិញអញ្ចឹងទៅពេលមកវិញគាត់យកយើងមកដល់ពេលក្រោយមកបាយទឹកអីរបស់ឆ្ងាញ់ៗគេមិនឲ្យយើងហូបទេខ្ញុំនៅចាំនិយាយពីខ្ញុំឃ្លានកាលពីជំនាន់ណុងឃ្លានអាផ្លែទឹកដោះនោះអីឃ្លានគាត់មិនឲ្យយើងញុំាទេគាត់ចិតញុំាតែខ្លួនគាត់ទេគាត់ចិតសំបកខ្ញុំមិនចង់និយាយទេណឹសខ្ញុំនៅក្មេងខ្ញុំនៅចាំខ្ញុំចង់និយាយអាមួយម៉ាត់នោះឲ្យអស់ចុះបើខ្ញុំនិយាយអត់ត្រង់ព្រះអើយ!ហើយគាត់ចិតអាសំបកនិងដាក់ក្នុងអាកន្ថោស្ពោះទឹកម៉ាត់គាត់ហូបម្លូណឹសគាត់ញុំាម្លូយាយនិងគេហៅគាត់យាយស យាយសហើយគាត់មូរតែថ្នាំលក់ទេ គីឡូគាត់ ណឹសគាត់មូរបាច់ៗយកទៅឲ្យគេណឹសហើយយប់និងគាត់ឲ្យខ្ញុំរៀនមូរដែរមូរទៅមូរមិនស្អាត់ល្អអីចេះតែមូរទៅនេះដែរណឹសហើយគាត់កាត់យកតែប្រុយៗចង់ជាបាច់យកទៅលក់និងហើយគាត់ទិញរបស់អីណាឆ្ងាញ់ៗគាត់យកមកហើយញុំាផ្លែទឹកដោះយើងនិងគាត់ចិតអាសាច់ញុំាអស់នៅសល់សំបកហើយនៅសល់និងវាមិនមានជាតិសាច់ខ្លះនោះដាក់គរនៅអាកន្ថោយើងនិងហើយខ្ញុំក្មេងខ្ញុំអត់ដឹងលូកយកអាសំបកនេះឯងយកមកកកេរយកមកញុំាយកអាសំបកនៅក្នុងនិងគាត់ឲ្យយកអាកន្ថោទៅចាក់ចោលអាកន្ថោសុទ្ធតែ

កាកយើងក្មេងយើងមិនដឹងអីទេនិងហើយយកអាសំបកនិងឯងមកញុំាខ្ញុំមិននិយាយទេហើយខ្ញុំខ្មាស់គេណាស់សូម្បីតែម្ដាយខ្ញុំក៏ខ្ញុំមិនដែលប្រាប់ដែរតពេលគាត់ឲ្យយើងជំរះស្មៅទៅដល់ល្ងាចអត់ឲ្យយើងឡើងផ្ទះទេឲ្យយើងជំរះណឹសជំរះអស់ប៉ុន្នេះណឹសចេះតែឈូសទៅម៉ាដុំអញ្ចឹងណឹសខាងមុខផ្ទះគាត់នោះឈូសៗទៅហើយគាត់ឲ្យដុតទៀតដុតស្មៅនិងអាណាក្រៀមៗឲ្យដុតហើយយើងនៅក្មេងសោះនិងណាដូចថាកាយម៉ាដុំៗអញ្ចឹងទៅដាក់ដុតទៅដុតហ៊ុយៗអញ្ចឹងទៅវាមានល្ងឹកមានអីតិចៗ។ឈូសៗទៅស្រាប់តែឃើញហ៊ីងណឹសវាចេញមកហ៊ីងឃ្លានយកអាហ៊ីងនិងទៅដុតនិងភ្លើងនិងឯងហែកអាហ៊ីងនិងអង្គុយស៊ីទៅខ្ញុំមិនចង់និយាយទេទើបតែចង់និយាយព្រះចង់ឲ្យខ្ញុំនិយាយខ្ញុំមិនដែលនិយាយប្រាប់អ្នកណាទេ។

ក៖ អ៊ុំដូចជាអ៊ុំនៅក្មេងអ៊ុំជួបទុកលំបាកអញ្ចឹងមានអារម្មណ៍ថាចុះចាញ់ទេ?

គ៖ ខ្ញុំឆ្អែតឆ្អន់ហើយអារឿងជួបទុក្ខលំបាកនិងមិនអស់ទេរឿងរាវខ្ញុំវែងឆ្ងាយណាស់ក្រោយមកក៏ខ្ញុំនៅ តែជួបដែរ ជួបអាមនុស្សបោកប្រាស់ដោយសារខ្ញុំត្រង់ខ្ញុំវាល្ងង់ ល្ងង់ហើយត្រង់ទៀត។

ក៖ ចាំ! យើងអ្នកទៀងត្រង់គេស្រួលណឹស។

គ៖ ត្រង់ហើយល្ងង់ទៀតជីវិតរបស់ខ្ញុំវាអត់ទាន់រីកចំរើនទេអញ្ចឹងបានខ្ញុំថាអ្វីដែលខ្ញុំកាត់រកមនុស្សដែលអាណិតហើយស្រលាញ់ខ្ញុំអាណិតខ្ញុំណាស់ខ្ញុំអត់ទាន់រកគេឃើញណឹសដែលគេប្រុងរកជួយខ្ញុំគេថាអស់ម៉ានអស់ចុះឲ្យអ្នកណារកខ្ញុំឃើញនិងបណ្ដាំគេនិយាយប្រាប់ណឹសបើគេឃើញគេជួយចិញ្ចឹមខ្ញុំហើយតែពេលនិងដូចភ្លេចភ្លាំខ្ញុំរកគេអត់ឃើញហើយគេក៏រកខ្ញុំអត់ឃើញបងខ្ញុំនិងណឹសហើយខ្ញុំក៏អត់បានស្រាវជ្រាវរកគាត់ដែរភ្លេចភ្លាំងៗរកគេឃើញបាត់ទៅហើយតែយើងអត់ប្រឹងតាំងពីដើមមកទើបតែឥឡូវនិងណឹសបើប្រឹងរកគេឃើញហើយហើយឲ្យគេទៅរកយើងឯណាបើមិនស្គាល់ភូមិសាស្រ្ត យើង អត់ដឹងយើងនៅឯណា ឯណាផងនិងអញ្ចឹងជួបគ្នានៅតាមតំបន់អញ្ចឹងពេលយើងចាកចេញពីស្រុកនិងទីកន្លែងនិងទៅឲ្យគេទៅរកយើងណារកគ្នាអត់ឃើញដល់ពេលអញ្ចឹង។អញ្ចឹងបានស្ដាយក្រោយនិងគេអាណិតខ្ញុំគេថាមានចិត្តអាណិតម៉ងគេរកឃើញគេចិញ្ចឹមខ្ញុំហើយគេផ្ដាំតាមគេណឹស អ្នកណាក៏ដោយតារកខ្ញុំឃើញគេជួយចិញ្ចឹមខ្ញុំជួលមើលថៃរខ្ញុំ
ហើយតែខ្ញុំអាសំដីអស់និងវាមានច្រើនដែលដឹងប៉ុន្តែខ្ញុំដូចអត់ខ្វាយខ្វល់ពីរឿងនិងសោះអញ្ចឹងខ្ញុំទ្រាំរស់នៅដូចថានិស្ស័យរបស់ខ្ញុំព្រហ្មលិខិតរបស់ខ្ញុំទៅខ្ញុំអត់ស្រវេស្រវាគេរកយើងហើយយើងអត់ព្រមប្រឹងប្រែងរកគេវិញទេទៅរកមនុស្សណាដែរគេជួយចិញ្ចឹមយើងជួយមើលយើងមិនងាយរកបានទេណឹសចាំ!មនុស្សសម័យឥឡូវទាល់តែធ្វើការឲ្យគេបានគេជួយយើងទាល់តែយើងមានប្រយោជន៍គេដែរបានគេជួយយើងគ្មានប្រយោជន៍អីសំរាប់គេគេមិនជួយយើងទេណឹសអញ្ចឹងខ្ញុំដឹង

ច្បាស់កន្លែងនិង។ចាំ!អញ្ចឹងអោយខ្ញុំទីពឹងបងប្អូនអីពឹងមិនបានទេ ពឹងមិន បានទេចាំ! ព្រោះបងប្អូនខ្ញុំរស់នៅដោយបងប្អូនខ្ញុំ ហើយខ្ញុំរស់ដោយខ្ញុំ។

ក៖ អញ្ចឹងអ៊ុំពឹងពាក់ដោយខ្លួនឯង!

គ៖ ចាំ!ពឹងពាក់ខ្លួនឯងរាល់ថ្ងៃនិងកូនគេធ្វើការបានតិចៗមកណាដោះស្រាយថ្លៃផ្ទះថ្លៃភ្លើងថ្លៃទឹកអីសព្វបែបយ៉ាងហើយយើងនៅតិចៗចេះតែចាយតិចៗអញ្ចឹងទៅអាលែងមើលចៅតាំងពីបានចៅមកខ្ញុំអត់សូវចេញទៅរកអីទៅធ្វើអីទេគ្រាន់តែខ្លួនឯងជរាពិការខ្ញុំពិការតាំងពីម្ដាយខ្ញុំ។ចាំ!គាត់ដឹងថាទៅមុខទៀតខ្ញុំមិនអាចធ្វើការអីធ្ងន់ទេបណ្ដាំពេទ្យមកថាមិនឲ្យធ្វើការធ្ងន់ទេចាំ!ហាមមិនឲ្យធ្វើការធ្ងន់ធ្វើការធ្ងន់ខ្ញុំធ្លាក់ខ្លួនឈឺចាំអញ្ចឹងគាត់ដឹងណឹសគាត់ដឹងច្បាស់កូននិងថ្ងៃក្រោយធ្វើការអីធ្ងន់មិនបានទេបានជួយគ្នាទៅខ្ញុំត្រូវគ្រាប់តាត្រូវសម័យឆ្នាំចិតជាងនៅក្មេងចាប់ផ្ដើមចេញពីខេត្តពោធិ៍សាត់ចេញពីគេមកគាត់មកយកខ្ញុំនៅជាមួយបានប្រហែលជា១ឆ្នាំនិងឯង!នៅជាមួយគាត់បានតែមួយឆ្នាំនិងខ្ញុំត្រូវ គ្រាប់ប៉ឹបធ្លាក់ខ្លួនពិការ។

ក៖ ប៉ុន្តែអត់ប៉ះពាល់ដល់ជីវិតទេ?

គ៖ ទៅមើលនេះនៅពេទ្យនេះឯងនៅខេត្តសៀមរាបនេះកាលជំនាន់ណុងនៅចាំដុកទឹតាឈ្មោះដុកទឹឆកសព្វថ្ងៃកូនកាលសម័យឪពុកឪពុកខំប្រឹងប្រែងមើលខ្ញុំម្ដាយខ្ញុំទៅសំពះអង្វរគេសុំឲ្យជួយកូនខ្ញុំបានរស់រានមានជីវិតផងព្រោះអីគាត់ពឹងយើងដែរពីដើមមកមានប្រយោជន៍ដោយសារយើងច្រើនដែរណឹ សបើខ្ញុំជួយគាត់ច្រើនដែរ ជួយអីជួយមិនដែលបានរស់នៅជាប់និងទ្រូងគាត់ដៃគាត់ខ្ញុំរស់នៅជាមួយគេគេតាំងពីខ្ញុំដឹងក្ដីពេលណាតិចៗខ្ញុំនៅជាមួយគេរហូតខ្ញុំនៅជាមួយគេតាំងពីអាយុគិតទៅ៧, ៨ឆ្នាំ, ៩ឆ្នាំនៅជាមួយគេក្មេងមែនទែន ចាំ! នៅជាមួយគេអត់ដែលបាននៅម្ដាយទេខ្ញុំនៅជាមួយបានតិចដែរខ្ញុំចង់នៅជាមួយម្ដាយយាយពីថាស្រលាញ់ម្ដាយអើយស្រលាញ់ចង់នៅក្បែរទ្រូងគាត់វាសុខណឹសវាស្រួលមិនធ្វើបាបយើងអត់មានស៊ីម្ដេចមួយម្ដាយយើងនៅមួយគេវាអត់ស្រួលម៉ង។ដឹងថាគេឲ្យយើងស៊ីក៏ឲ្យអត់សប្បាយចិត្តគេឲ្យមិនសប្បាយចិត្តទេហើយគេបានរបស់អីញ៉ាំគេញ៉ាំតែគេទេកំរទំរមតែរបស់និងសល់នោះអញ្ចឹងទៅណឹសបានមកដល់យើងបើគេទិញមកថ្មីៗគេទិញមកទុកញ៉ាំហើយអារបស់ណាឆ្ងាញ់ៗគេទុកញ៉ាំខ្លួនគេខ្ញុំមិនដែលបានញ៉ាំបានរបស់ឆ្ងាញ់ទេបានតែកាកសំណល់គេទេដែលគេញ៉ាំសល់អីនិងបានបានណឹសបើថារឿងឲ្យគេនេះរបស់គេល្អៗកំរណាស់អញ្ចឹងបានថាខ្ញុំ ស្គាល់ អស់ហើយ។

ក៖ ចុះដូចថាលោកតាលោកយាយខាងឪពុកអ៊ុំស្គាល់គាត់ទេ? អើតាយាយរបស់អ៊ុំណឹស ឪពុកម្ដាយ ខាងឪពុកអ៊ុំណឹស អ៊ុំស្គាល់ទេ?

គ៖ តែគាត់ទៅក្រៅដែរណឹស តាគាត់ស្លាប់នៅក្រៅប្រទេសដែរណឹស គាត់ឈ្មោះញ៉េប ទូច ហើយនៅស្រុកអាមេរិកគេហៅយាយធំយាយធំអញ្ចឹងណឹសដល់ពេលក្រោយមកគាត់ធំគាត់ចេះតែធាត់ទៅៗខ្លះគេហៅគាត់ថាយាយធំៗអញ្ចឹងទៅដល់ពេលឈ្មោះគាត់ដាក់យាយទូចអញ្ចឹងណឹស។

ក៖ ទូច ដល់ទៅនៅក្រៅហៅធំ។

គ៖ ចាំ! គេហៅថាយាយធំៗ ដល់គាត់ស្លាប់ៗនៅស្រុកគេតែក្រោយមកពីដើមខ្ញុំទាក់ទងគាត់ គាត់ទាក់ ទងមកខ្ញុំ។ ខ្ញុំខំស្រាវជ្រាវរកគាត់ឃើញហើយ ពូម៉ាមីងខ្ញុំនិងណឹសទៅខំស្រាវជ្រាវរកអែតត្រេសបានអីមកឲ្យខ្ញុំកាលពីដើមឡើយណឹសតែឥឡូវគាត់ស្លាប់ហើយគឺខ្ញុំទ្រាំអត់រហូតតាំងពីពេលនោះមក។ ខ្ញុំ ទឹសកាលអីទៅប្រាប់អាប្អូនមិនមែនឪពុកជាមួយគ្នានោះទៅប្រាប់ត្រង់ណែអូនអើយបងរកអែតត្រេសយាយឃើញហើយឯណាបងឯណាកត់ឲ្យទៅកត់អែតត្រេសនេះទៅឲ្យអាប្អូននេះទៅអាប្អូននៅភ្នំពេញកាលណុងគេអត់ទាន់មានប្រពន្ធទេកាលណុងគេទៅធ្វើទាហានអីពេទ្យណឹសគេទៅធ្វើពេទ្យទាហាននិងឯងដល់ទៅគេវាយគ្នាពេកក៏មកគេចុះមកវិញដល់បាត់ដំបងវិញគេមកស្រាវជ្រាវរកក៏មកដេក នៅនិងមួយយប់ទៅខ្ញុំក៏ប្រាប់វាទៅចុះខ្ញុំវាត្រង់នោះត្រង់ជាមួយបងប្អូននោះអត់មាននឹកឃើញថាលាក់ លៀមអីសោះក៏ឯណាៗបងកត់អានោះវាអ្នកចេះវាបានរៀនបានសូត្រចេះទាំងភាសាខ្លះទៀតភាសាអង់គ្លេសវាចេះក្បួនពេទ្យអីវាចេះអរ!ឯណាបងឯណាអែតត្រេសគេទាំងអស់គេកត់អីទាំងអស់កត់យកអែតត្រេសនិងទៅបាត់ទៅ ទៅនៅឯស្រុកណឹសក្រោយមកគេទៅនៅភ្នំពេញតាមបងធម៌គេ គេមា នបងធម៌គេដែរបងប្រុសគេកាន់សាសនាគ្រឹស្ទអីទៅតាមបងគេបានប្រពន្ធនិងបែកផ្ទះបែកអីហើយផ្ញើអាលុយនិងឯង អូស! ផ្ញើអាអែតត្រេសនិងឯងចាក់ទៅតាមអង្គការគេណឹស ចាក់ទៅផ្ញើរទៅយាយនិងដល់ឲ្យយាយនិងនឹកឃើញវាផងយាយស្គាល់ខ្ញុំអត់លោកយាយខ្ញុំជាចៅដែរឈ្មោះនេះឈ្មោះនោះ យាយពរបីដែរតាលឺសូរគេនិយាយណឹស ថាយាយពរបីខ្ញុំដែរតានៅក្រោមដើមចន្ទដើមអីនិងចៅតប ចេះៗស្រលាញ់ចៅណាស់វានៅមួយគេចេះៗដាក់ទៅក៏ក្រោយមកផ្ញើរលុយតាមវានិងឯងផ្ញើរលុយតាមវាឡើងប៉ុន្មានរយដុល្លាអញ្ចឹងទៅក៏បានលុយនិងថាចែកមកខ្ញុំផងចែកមកម្ដាយវាមានឲ្យយើងណាវាប្រមូលលុយនិងទាំងអស់ការប្រពន្ធហើយវាអត់ហៅយើងវាអត់ហៅម្ដាយក៏វាមិនហៅអាយើងបងនេះក៏វាមិនហៅវាការជាមួយបងធម៌វានិងអញ្ចឹងបានខ្ញុំថាបងប្អូនខ្ញុំវាពិបាកមែនទែន ដើម្បីតែខ្លួនវា ទេហើយខ្ញុំវាត្រង់ក៏ឲ្យអែតត្រេស ក្រោយបើឲ្យទៅអាប្អូនមួយទៀតបាន ចាំ! អាប្អូនមួយទៀតវាអត់មាន អីបែកពីម្ដាយដែរវាកំសត់ណឹសកំសត់ណាស់ខ្ញុំអាណិតវាណាស់ពីតូចម្ដាយខ្ញុំជួយតែកូនប្ដីមុនប្លែងចោលទាំងអស់គាត់អោបតែអាកូនប្ដីក្រោយនេះឯងអញ្ចឹងខ្ញុំអត់ប្រ

ណែនទេអាប្អូនខ្ញុំនឹកឃើញថាបើខ្ញុំ ទុកអែតត្រេសឲ្យវាទៅ អាប្អូនខ្ញុំអាកំសត់នេះវាអត់បានរៀន
បើសិនជាបានតែធ្លាក់ទៅតែមួយនិង ១, ២ បានអាអ្នកខឹលខូចអីនិងបើបានអានោះមួយទៀត
កូនប្ដីគាត់ក្រោយនិងវាបានលុយមកយកទៅទិញជិះផឹកស៊ីស្រវឹងវាហៅគ្នាពួកម៉ាក់វាទិញម៉ូតូក៏វា
អត់ពិភាក្សាជាមួយយើងដែរវាទៅទិញតែខ្លួនវាហើយវាផឹកស៊ីអីតែខ្លួនវាស្រវឹងវាជិះវាអីចូលឡាន
អញ្ចឹងទៅម៉ូតូនិងវាចង់លក់ចេញទៅវិញក៏វាលក់ទៅណឹសហើយវាមកនៅជាមួយយើងស៊ីចុកបុក
ទំពាហើយចង់ទិញអីវាឧបគ្នាវាទៅពិភាក្សា អត់ហៅយើងជា បងទៅពិភាក្សាទេ។ លុយកាកអី
ហើយវាច្រណែនជាមួយយើងបើសិនជាថាខ្ញុំនៅតែទាក់ទងជាមួយមកបងប្អូនខ្ញុំទៀតមានការច្រ
ណែនយ៉ាងខ្លាំងវាលួចសំលាប់យើងណឹស ខ្ញុំអត់ទុកចិត្តទេបងប្អូនខ្ញុំ បើសិនជាយើងមានលើវា
យើងមានដុល្លាយាយនិងទាក់ទងខ្ញុំមួយទេហើយផ្ញើរឲ្យខ្ញុំរាល់ខែទៅណឹសច្បាស់ជាប្អូនខ្ញុំមានការ
ច្រណែននិងខ្ញុំ ខ្ញុំមានការភ័យព្រួយទ្រព្យសម្បត្តិក៏មិនដែរខ្ញុំឃើញខ្សែភ្នែករបស់
វាលួចធ្វើបានយើង។

កៈ ពិបាកដែរមនុស្សមិនធ្លាប់រស់នៅជាមួយគ្នា។

គៈ ចា៎!ខ្ញុំនៅមិនទុកចិត្តអាកន្លែងនិងអញ្ចឹងបានខ្ញុំថាក្រក៏ម្យ៉ាងដែរពិបាកក៏ម្យ៉ាងដែរបើសិនជា
យាយនិងយាយខ្ញុំនិងពីដើមមកគាត់ដាក់ក្នុងសំបុត្រមកឲ្យខ្ញុំនិងមើលការខុសត្រូវប្អូនទាំងអស់១០
និងអាណានៅណាឲ្យគាត់ដឹងផងធ្វើអញ្ចឹងដែរដល់ពេលចាប់ពីខ្ញុំបំបែកអែតត្រេសមកឲ្យវាអាប្អូន
ទី១,ទី២,ទី៣,អានិងទី៣អើ!មើលខ្ញុំទី១,សុខយេងទី២,ទី៣អារុធ,អានិងទី៤និងវាយកខ្ញុំអោយអែត
ត្រេសទៅនិងបំបែកដល់ពេលអាទី៥,អាទី៦នេះក៏ខ្លាំងដែរគេចង់បានប្រពន្ធបានអីនិងហើយគេដា
ក់សំបុត្រ សំអីទៅណឹសក៏ផ្ញើរមកឲ្យយាយហើយយាយទទួលដល់ហើយវាទៅទិញម៉ូតូហើយ
ចិញ្ចឹមវាទៀតចិញ្ចឹ មវា ជួយវាទាំងអស់ វាមកនៅជាមួយយើងស៊ីលើយើង ហើយកាណុង
កំពុងក្រអត់ផងចិញ្ចឹមវាទាំងអស់អញ្ចឹងបានថាដល់ពេលក្រោយមកវារាងប្រមាថយើងប្រសិនបើ
យើងជាយើង(ភ្លេចអស់ហើយធាតុដើម)ទទួលអាលុយនិងណឹសផ្ដាច់ពីនេះយើងត្រូវពិបាកខ្ញុំដេក
អត់លក់ទេបិទភ្នែកអត់លក់ ដេក រស់ នៅក៏យើងអត់សុខដែរ វាវាយតម្លៃយើងវាថាយើងអាង
អញ្ចឹងបានថាអ្នកមានដុល្លាខ្លះគេធ្វើអំពើបង គេធ្វើអំពើប្អូន សំលាប់ប្អូន កាប់បងកាប់ប្អូនដោយ
សារអាដុល្លានិងក៏មានដែរមិនទៅច្រើនអីអាតិចតួច អី៤០០, ៥០០ក៏វាច្រណែនយើងដែរ
អា២០០,៣០០និងក៏វាច្រណែនយើងដែរអញ្ចឹងបានថាពេលដាក់ សំបុត្រមកយាយចំៗថា
ចៅសុខឃីមយើងធ្វើអត់ត្រឹមត្រូវទេចៅមានហើយចៅរស់នៅដូចថាចង់យាយថាមិនជានរណាគេ
ដាក់សំបុត្រទៅទេប្រាប់គាត់ថាខ្ញុំនិងមានហើយមិនដឹងជាថាខ្ញុំធ្វើអីគេទេខ្ញុំគាត់ដាក់ក្នុងសំបុត្រថា
ចៅសុខឃីមចៅដូចថាអាចមានលទ្ធភាពមានហើយអញ្ចឹងចំណែកនិងអត់មានយើ ងទេ

អញ្ចឹងមនុស្សគេតែ មិនដឹងថាបងប្អូនយើងកែពាក្យនិងហើយគាត់ដាក់មក ហើយខ្ញុំអស់ចិត្តតាំងពីពេលនោះមក ឃើញទេវាអត់ត្រង់ជាមួយខ្ញុំទេពេលខ្ញុំបំបែកអែតត្រេសនិងទៅឲ្យវា វាខ្លាចខ្ញុំអញ្ចឹងណឹ សវាអត់ត្រង់ជាមួយយើងទេ។

ក៖ អ៊ុំមានកូនប៉ុន្មាននាក់ដែរ?

គ៖ ខ្ញុំមានកូនតែ២។

ក៖ ២ នាក់ណេះ។

គ៖ ចាំ! ប្រុស១ ស្រី១ មានតែប៉ុណ្ណឹង។

ក៖ អូ! បងទី១នរណាគេដែរអ៊ុំ?

គ៖ មីអូននិងឯង។

ក៖ គាត់ឈ្មោះអីដែរអ៊ុំ?

គ៖ ឈ្មោះដើមកំណើតឈ្មោះ វាអត់ស្រលាញ់ឈ្មោះនិងវាដូរមក ឡាមុត ចិត្រានិងវិញ វាសុខា។

ក៖ តែគាត់ស្រលាញ់ឈ្មោះចិត្រា។

គ៖ ដូរតាំងពីសម័យវារៀន។

ក៖ ចុះកូនប្រុសរបស់អ៊ុំ?

គ៖ ឈ្មោះចាន់ ដារាឡាមុត អត់ច្បាស់ផងតានិងអ្នកដាក់ឈ្មោះឲ្យសរសេរណឹសព្រោះគាត់ជាអ្នកសរសេរព្រាងទុកកាលវានៅរៀននៅអីអញ្ចឹងណឹសជួយឲ្យរៀន។

ក៖ ចុះមិថុនាគាត់ជាកូនរបស់អ្នកណាគេ?

គ៖ កូនអាប្រុស។

ក៖ អូ!ចិត្រា។អញ្ចឹងអ៊ុំមានចៅម្នាក់ហើយ។ហើយដូចជាអ៊ុំសំរាប់អ៊ុំក្រៅពីភាសាខ្មែរអ៊ុំមានចេះភាសា អ្វីផ្សេងទេ?

គ៖ អ៊ុំពីដើមអ៊ុំរៀនអង់គ្លេសខ្លះៗដែរនិងហើយចេះតែមានបញ្ហាមួយតាទៅគាត់ខឹងគាត់ហែកសៀវភៅចោលតាគាត់ខឹងគាត់ហែកសៀវភៅខឹងនោះតាំងពីណុងមកអ៊ុំក៏បោះបង់ចោលទៅអ៊ុំរៀនពីដើ

មឲ្យតែយកចិត្តទុកដាក់រៀនចេះដែរតាយាយស្តាប់បានដែរតាចាំ!អង់គ្លេសរៀនជាអក្សរតែអ៊ុំអត់ស្វរចេះខ្មែរទេប៉ុន្តែដូចថារៀនទៅវាចេះតែបែកអញ្ចឹងទៅតិចៗអញ្ចឹងណឹសបែកទៅរៀនជាមួយពួកពេទ្យអស់និង គេប្រុងឲ្យអ៊ុំរៀនចប់អស់ចូលបុក២ ចុះកាលណុងគេរៀនសៀវភៅបុក១, បុក២ចូលបុក២គេជួយអ៊ុំចូលពេទ្យពេទ្យធ្មបនិងហើយដល់ពេលទៅកំពុងតែរៀនអាបុក១និងជិតតិចទេមានអីតាគាត់ខឹងទៅគាត់ហែកសៀវភៅអីកាច់ប៉ិចកាច់អីចុះហែកសៀវភៅហើយកំពុងអត់លុយមិនដឹងទៅរកទិញសៀវភៅឯណាអាសៀវភៅកំរាស់នេះថ្លៃផងអត់មានអត់អីបានអាសៀវភៅនិងអីយើងអាចបើកមើលបករាល់តែ ថ្ងៃទៅដល់ពេលគាត់ហែកអស់ខ្ទេចអស់អញ្ចឹងបានអី បើសិនជាអ៊ុំអ៊ុំនឹកឃើញបើសិនជាអ៊ុំជួបបងអ៊ុំជួបអ្នកនៅកាណាដាជួបអីអ្នកដែលបែកនោះអ៊ុំនិងប្រឹងរៀនទោះបីជាអ៊ុំចាស់ប៉ុន្នេះអីនៅស្រលាញ់ភា សាអញ្ចឹង ចង់ចេះ។

ក៖ អ៊ុំរៀនដល់ថ្នាក់ទីប៉ុន្មានពីក្មេង?

គ៖ អត់បានរៀនទេដូចអ៊ុំនិយាយអញ្ចឹង។

ក៖ តាអង់គ្លេសទេ?

គ៖ អត់ទេអង់គ្លេសទើបតែចាប់ផ្តើមមានប្តី មានគ្រួសារហើយនេះ
យើងទៅនៅជាយខ្ញុំរៀនបានខ្លះៗ អង់គ្លេសនិងណឹស ចាំ! ហើយខ្មែរនោះបានរៀនបានតិចៗ
ដូចពីដើមតាំងពីក្មេងគេមិនឲ្យយើងរៀនទេ គេមិនឲ្យយើងស្គាល់សាលាអីទេដូចសម័យនេះ
គេឲ្យកូនរៀនតាមសាលាតាមអីអាម្តេចក៏ត្រូវតែចេះ ពីដើមគេមិនឲ្យយើងចេះទេ គេឲ្យយើង
បំរើគេដឹងតែបំរើគេហើយអត់មានមកឲ្យចេះទេ។

ក៖ អ៊ុំពីក្មេងមានបំណងប្រាថ្នាចង់ធ្វើអ្វីបន្ទាប់ពីធំឡើង?

គ៖ ខ្ញុំពីក្មេង អារឿងប្រាថ្នាចង់ទី១ ខ្ញុំចង់ចេះខ្មែរឲ្យច្បាស់ ចេះភាសានិងឲ្យច្បាស់អីស្រលាញ់ភាសាយាយទៅសព្វថ្ងៃនៅតែចង់ស្រលាញ់ភាសាតែមិនដឹងធ្វើម្តេចដើម្បីខំរៀនឲ្យចេះនិយាយចង់ចេះភា សានិងខ្លាំង។

ក៖ អញ្ចឹងដូចជាសំលេងមួយនេះ ចៅមិថុនាបានស្តាប់អញ្ចឹងអ៊ុំនិយាយជាចុងក្រោយប្រាប់
គាត់បានទេ ថាអ៊ុំ អ៊ុំចង់រៀនមែនទេ? អញ្ចឹងអ៊ុំអាចនិយាយមកថា លើកទឹកចិត្តគាត់ថាចង់
ឲ្យចៅខំប្រឹងរៀនសូត្រដើម្បីអនាគតអញ្ចឹងណឹសហើយអ៊ុំមានបំណងអ្វីសំរាប់គាត់ណឹសអ៊ុំអាចនិយាយបាន។

គះ ចាំ! អ៊ុំមានបំណងចង់ឲ្យកូនចេះ អ្វីដែលអ៊ុំស្រលាញ់និងណឹសគឺភាសានិងចង់ឲ្យចេះខ្លាំង ចង់ឲ្យចេះកុំឲ្យល្ងង់ម៉ងហើយធំឡើងចង់ឲ្យកូនបំរើព្រះពិតប្រាកដអត់ឲ្យធ្វើប្លាក់ប្លងអីនៅក្រៅអីទៀតទេចង់បែកធ្វើអីផ្សេងៗទៀតចង់ឲ្យចេះភាសានិងឲ្យបានច្បាស់លាស់បំរើព្រះអីអញ្ចឹងណឹស ។

កះ ហើយដូចជាសំនួរចុងក្រោយដែលខ្ញុំចង់សួរដោយសារខ្ញុំអត់មានអីច្រើន អញ្ចឹងអ៊ុំអាចអនុញ្ញាតឲ្យ ខ្ញុំដាក់សំលេង និងរូបថតអ៊ុំនៅក្នុងវើបផ្សាយរបស់យើងបានដែរទេ?

គះ អ៊ុំចង់ដាក់ចេះ បើចង់ដាក់ទៅណឹសតែដាក់ឈ្មោះអ៊ុំ កុំយកឈ្មោះណៃក្នុងអត្តសញ្ញាណប័ត្រទៅ ដាក់អីណឹស យើងដឹងថាឈ្មោះយើង៣ហើយ នៅក្នុងអត្តសញ្ញាណប័ត្រឈ្មោះសុខឃើមអញ្ចឹងណឹស តែឈ្មោះទីមួយនៅសម័យប៉ែតជាងឈ្មោះ អាធីណឹសរស់នៅណាកាលសម័យជំនាន់ទី គឺខ្ញុំរស់នៅជិត វត្តកេតសារ៉ាមនេះ ភូមិតាភុលនេះឯងពីដើមយើងរស់នៅជាមួយយាយ មានអ្នកចង់ស្រាវជ្រាវអញ្ចឹង ណឹស។

កះ អ្នកមីងនិង អ្នកមីងនាង?

គះ ខ្ញុំឈ្មោះ អើ! យាយចេះអាសុខធីមកណឹសអញ្ចឹងពីដើមមកកាលពីសម័យប៉ែតជាងនិងម្តាយចិញ្ចឹ មជាអ៊ុំ ខ្ញុំហៅគាត់អ៊ុំណឹសប៉ុណ្ណឹងនៅជិតភូមិតាភុលនេះនៅជិតវត្តកេតសារ៉ាមគេហៅវត្តធម្មយុត្តិ ចាំ! អញ្ចឹងខ្ញុំចង់ឲ្យផ្សាយកន្លែងនិងឲ្យបងប្អូនខ្ញុំរកឃើញផងណឹស។

កះ អញ្ចឹងអ៊ុំអនុញ្ញាតឲ្យខ្ញុំដាក់?

គះ ចាំ! ដាក់ទៅដាក់ឈ្មោះទាំង៣និងណឹស។

កះ ហើយខ្ញុំអត់មានអីច្រើនដែរមានតែប៉ុណ្ណឹងហើយខ្ញុំសូមអរគុណអ៊ុំហើយការសំភាសន៍ក៏ត្រូវបាន បញ្ចប់។ អរគុណច្រើនអ៊ុំ។